


# អនុវិទ្យាល័យ

## អ្វីដែលបានរៀនសូត្រនៅអនុវិទ្យាល័យអាចបន្តស្ថិតនៅពេញមួយជីវិតស្របពេលសិស្សានុសិស្សចេញស្វែងយល់និងរុករកនូវអ្វីដែលជាចំណាប់អារម្មណ៍ ដែលនឹងក្លាយជាតម្រូវការពេញមួយជីវិត។

អនុវិទ្យាល័យ (ពីឆ្នាំទី ៧ ដល់ទី ៩) គឺជាពេលវេលាមួយដ៏សំខាន់និងពេលខ្លះក៏ពិបាកក្នុងការផ្លាស់ប្តូរពីភាពជាកុមារទៅជាមនុស្សជំទង់។សិស្សានុសិស្សចាប់ផ្តើមយល់ដឹងអំពីអត្តសញ្ញាណរបស់ពួកគេ សាកល្បងនូវព្រំដែនរបស់ពួកគេ និងទទួលបានការយល់ដឹងអំពីសក្តានុពលនិងទីកន្លែងរបស់ពួកគេនៅក្នុងពិភពលោក។

កម្មវិធី មុខវិជ្ជាសិក្សា និងបរិយាកាសនៅក្នុងអនុវិទ្យាល័យរបស់យើងត្រូវបានរៀបចំឡើងយ៉ាងពិសេស ដើម្បីជួយដល់ការអភិវឌ្ឍខ្លួននិងការសិក្សារបស់សិស្សានុសិស្ស ក្នុងអំឡុងពេលនៃការផ្លាស់ប្តូរនិងការលូតលាស់ដ៏រំភើបនេះ។បុគ្គលិកប្រចាំអនុវិទ្យាល័យយល់ថា តុល្យភាពរវាងព្រំដែនដ៏រឹងមាំនិងការហ៊ានប្រថុយប្រថានគឺចាំបាច់សម្រាប់មនុស្សជំទង់ ហើយបុគ្គលិកជំនាញ រួមទាំងអ្នកប្រឹក្សាប្រចាំអនុវិទ្យាល័យ នឹងជួយគាំទ្រសិស្សានុសិស្សនៅគ្រប់ដំណាក់កាលនៃការធ្វើដំណើររបស់ពួកគេ។

ជំរើសនៃមុខវិជ្ជាសិក្សាដែលមានស្រាប់នឹងកើនឡើងបន្តិចម្តងៗ ស្របពេលសិស្សានុសិស្សកំពុងសិក្សានៅអនុវិទ្យាល័យ ដោយសិស្សម្នាក់ៗនឹងត្រូវបានស្នើឱ្យជ្រើសរើសកម្មវិធីសិក្សារបស់ខ្លួនផ្ទាល់។ ពីឆ្នាំទី ៧ ដល់ទី ៩ ជម្រើសជាច្រើននឹងត្រូវបានផ្តល់ឱ្យ ដែលអនុញ្ញាតឱ្យសិស្សានុសិស្សចាប់យកកម្មវិធីសិស្សាទៅតាមចំណាប់អារម្មណ៍ និងតម្រូវការរបស់ខ្លួន និងស្វែងយល់នូវមុខវិជ្ជាជាច្រើន មុនពេលពួកគេកំណត់នូវវគ្គសិក្សាសម្រាប់ឆ្នាំចុងក្រោយនៃការសិក្សារបស់ពួកគេ។

បទពិសោធន៍នៅអនុវិទ្យាល័យនឹងឈានដលកម្រិតខ្ពស់បំផុតនៅឆ្នាំទី ៩ ក្នុងកម្មវិធីបរិស្ថានទីក្រុងសហគមន៍ (CUE)។ កម្មវិធីសិក្សាប្រកបដោយបទពិសោធន៍នេះផ្តល់នូវសកម្មភាពនានាដែលដឹកនាំដោយគ្រូគង្វាលនិងផ្តល់នូវចំណេះដឹងអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សិស្សអំពីសហគមន៍មូលដ្ឋានរបស់ពួកគេ ក៏ដូចជាបង្កើនការទទួលស្គាល់នូវវត្តមានរបស់ប្រទេសអូស្ត្រាលីនៅក្នុងតំបន់អាស៊ីទាំងមូល។ សិស្សានុសិស្សនឹងចូលរួមក្នុងសកម្មភាពក្រៅថ្នាក់រៀនដែលបង្កើតឡើងដើម្បីអភិវឌ្ឍនូវឯករាជ្យភាព គំនិតផ្តួចផ្តើម និងការធ្វើការជាក្រុម និងផ្តល់ឱ្យសិស្សានុសិស្សនូវបទពិសោធន៍និងទស្សនៈថ្មីៗ។ កម្មវិធី CUE មានរួមបញ្ចូលនូវបទពិសោធន៍ដ៏ធំមួយ គឺការធ្វើដំណើររយៈពេលបីសប្តាហ៍ទៅកាន់ប្រទេសមួយនៅអាស៊ីអាគ្នេយ៍ ឬ ដែនដីភាគខាងជើងនៃអូស្ត្រាលី <1)ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើសេវាកម្មនិងនិរន្តរភាពបរិស្ថាន។